**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| | |
|---|---|
| **តុលាការកំពូល** | **តាងនាមប្រជារាស្ត្រខ្មែរ** |
| សភារដ្ឋប្បវេណី | **តុលាការកំពូល** |
| សំណុំរឿង រដ្ឋប្បវេណី | បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៧ |
| លេខ: ៥១ | ខែ កក្កដា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅ: |
| ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ១៩៩៨ | ១- ឯកឧត្តម ........... ជាប្រធាន |
| **សាលដីកា** | ២-លោក ................ ជាចៅក្រម |
| លេខ: ១៤៩ | ៣- លោក .............. ជាចៅក្រម |
| ចុះថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ១៩៩៨ | ៤-លោក .............. ជាចៅក្រមរបាយការណ៍ |
| | ៥-លោក ................ ជាចៅក្រម |

**ក្រឡាបញ្ជី**

កញ្ញា ......................

**តំណាងមហាអយ្យការ**

លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៧៥៤ ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៩៧នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៦៦ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍

រវាងម្ចាស់បណ្តឹងលសាទុក្ខឈ្មោះឡុបណរអាយុ៣៣ ឆ្នាំ ជាតិខ្មែរ ភេទ ស្រីមុខរបរនៅផ្ទះ ទីលំនៅផ្ទះលេខ៥០អឺ២ ផ្លូវ១៦៦ ក្រុម៦១ សង្កាត់អូរឫស្សី ខណ្ឌ៧មករា ។ ឪពុកឈ្មោះឡេង ទ្រី "ស" ម្តាយឈ្មោះតៃ គឹមឆេង "ស" ។

នឹងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះពយ អាយុ៣៩ឆ្នាំ ជាត់ខ្មែរ ភេទស្រី មុខរបររាប់លុយ ទីលំនៅផ្ទះលេខ ២៦ ផ្លូវលេខ៣៧៤ ក្រុម៣៨០ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន ។ឪពុកឈ្មោះពិត ឈឿង "ស"ម្តាយឈ្មោះ ហាក់ឆេង "ស" ។ ឈ្មោះពយ បានផ្ទេរសិទ្ធិអោយឈ្មោះខេង ប៊ុននី ។

**កម្មវត្ថុបណ្តឹង** ៖ ប្តឹងទាមទារប្រាក់

តាមបណ្តឹងសាទុក្ខលេខ១៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៨ របស់ឈ្មោះអ្នកស្រីឡុបណរបានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ៧៥៤ ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៥១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១១.១២.១៦ របស់ឈ្មោះពយ ប្តឹងទាមទារប្រាប់ពីឈ្មោះឡុបណរចំនួន ២.៥០០ដុល្លាអាមេរិក ដោយសំអាងហេតុថាកាលពីខែ៧ ឆ្នាំ១៩៩៤ ឈ្មោះឡុបណរបានខ្ចីប្រាក់ខ្លួនចំនួន ២.៥០០ ដុល្លាអាមេរិក រហូតមកដល់ពេលនេះមិនព្រមសងទេ ។ ខ្លួនសំណូមពរទាមទារប្រាក់ចំនួន២.៥០០ដុល្លាអាមេរិក ទាមទារជំងឺចិត្ត

និងការប្រាក់ចំនួន១.០០០ ដុល្លាអាមេរិក ។ បើគ្មានប្រាក់សងសុំអោយតុលាការដាក់គុកបង្ខំដល់រូបកាយ នឹងរឹបអូសទ្រព្យសម្បត្តិលក់យកប្រាក់សងខ្លួន ។

បានឃើញសាលក្រមលេខ៣៦ "ក" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី១១.១២.១៩៩៦មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បង្គាប់អោយឈ្មោះឡុបណរជាចុងចម្លើយសងប្រាក់ចំនួន២.៥០០ដុល្លារ(ពីរពាន់ប្រាំរយដុល្លាអាមេរិក) និងការប្រាក់៥ភាគរយ ក្នុង១ឆ្នាំ គិតពីខែ៧-១៩៩៤ រហូតដល់ថ្ងៃអនុវត្តសាលក្រមនេះ និងជម្ងឺចិត្តចំនួន២៥០ដុល្លារ (ពីររយហាសិបដុល្លាអាមេរិក) អោយទៅដើមចោទឈ្មោះពយ វិញតាមមាត្រាទី៥៩ នៃក្រឹត្យច្បាប់លេខ ៣៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីចុះថ្ងៃទី២៨.១០.១៩៨៨ ។

៣- ក្នុងករណីឈ្មោះឡុបណរពុំព្រមសងប្រាក់ជំពាក់ទៅអោយឈ្មោះពយ នោះទេ សម្រេចរឹបអូសផ្ទះលេខ៥០អឺ ០ ក្រុម២១ ផ្លូវ១៦៦ សង្កាត់អូរឫស្សីទី២ ខណ្ឌ៧មករា ក្រុងភ្នំពេញ ដើម្បីទុកលក់ជានាសំណងដល់ឈ្មោះ ពយ ចាប់ពីថ្ងៃប្រកាសសាលក្រមតទៅ និងសម្រេចដាក់គុកបង្ខំរូបកាយតាមមាត្រា១៣៣ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីក្នុងករណីចុងចម្លើយរឹងទទឹងមិនព្រមសង ។

៤- បង្គាប់អោយឈ្មោះឡុបណរបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១.៨០០៛ រង្វាន់ក្រឡាបញ្ជី២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ២.០០០៛ រង្វាន់សាក្សី៣.០០០៛ សរុប៧.០០០៛ ដែលដើមចោទបានបង់ទុកជាស្រេចកាលបើហួសកំណត់ ឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយសងប្រាក់៧.០០០៛ អោយទៅដើមចោទវិញ និងអោយបង់ពន្ធសមាមាត្រមួយភាគរយ លើតម្លៃប្រាក់ជំពាក់ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយនិងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយ ។

៥- សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខភាគី សម្រេចបើកផ្លូវឧទ្ធរណ៍រយៈពេលពីរខែ ចាប់ពីថ្ងៃប្រកាសសាលក្រមតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៣ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧ របស់អ្នកស្រីឡុបណរដែលប្តឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ៣២ "ក" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញលើចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ៧៥៤ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០.៥.១៩៩៧ របស់ឈ្មោះឡេង ប៊ុណ្ណារី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុសនិងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៣៦ "ក" ចុះថ្ងៃទី០២.៤.១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣- សម្រេចកាត់យកប្រាក់ប្រដាប់ដក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០រៀល ។

៤- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។

សម្រេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៤៨ របស់អ្នកស្រីឡេង ប៊ុណ្ណារី ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៨ របស់ឈ្មោះឡុបណរ។

បាន ឃើញសារណាតបចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះ ខេង ប៊ុននី ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍បានសម្រេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ឡេង ប៊ុនណ្ណារី ជាចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខបានឆ្លើយនៅពេលសវនាការថា៖ លុយចំនួន២.៥០០ដុល្លា អាមេរិកនេះឈ្មោះពយ បានយល់ព្រមទូទាត់អោយឈ្មោះចាន់ ស៊ីណា វិញដោយគិតការប្រាក់ក្នុងមួយខែ២៥០ដុល្លាអាមេរិក ក្នុងរយះពេល ៥ ទៅ ៦ខែ ។ ឯរឿងកិច្ចសន្យាផ្តេតមេដៃសងលុយទៅអោយឈ្មោះពយ ក្នុង១ខែ ២០ដុល្លាអាមេរិកនោះ គឺដោយសារឈ្មោះគ្រុយ ត្រូវជាបងប្អូនពយ គំរាមគំហែង ។ ហើយពេលខ្លួនយកលុយទៅសងនៅកន្លែងនគរបាល នគរបាលពុំព្រមទទួលថាអោយខ្លួនចាំជួបម្ចាស់គេ លុះពេលម្ចាស់គេមកគេថាមិនយកទេ២០ដុល្លាមេរិក ក្នុង១ខែ ។ ហេតុនេះសូមតុលាការជួយរកយុត្តិធម៌អោយខ្លួនផង ។

បានស្តាប់ចម្លើយរបស់លោកខេង ប៊ុននី ជាដើមចោទ និងជាម្ចាស់បណ្តឹងទុក្ខ ដែលបានឆ្លើយនៅពេលសវនាការថា៖ បានជាខ្លួនប្តឹងមកតុលាការព្រោះអ្នកស្រីមិនគោរពកិច្ចសន្យា ។ ចំណែកប្រាក់ ២០ដុល្លាអាមេរិក ក្នុង១ខែក៏គាត់មិនអោយដែរ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា៖ បណ្តឹងសាទុក្ខលេខ១៧ ចុះថ្ងៃទី ១៤.០១.៩៨ របស់អ្នកស្រីឡេង ប៊ុនណ្ណារីធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា៖ អ្នកស្រីឡុបណរពិតជាបានជំពាក់ប្រាក់អ្នកស្រី ពយចំនួន២.៥០០ដុល្លាអាមេរិកប្រាកដមែន ។ ដូច្នេះអ្នកស្រីមានកាតព្វកិច្ចត្រូវសងប្រាក់នេះទៅម្ចាស់បំណុលតាមមាត្រា២២ នៃក្រឹត្យច្បាប់លេខ៣៨ ក្រច ចុះថ្ងៃទី ២៨.១៩.៨៨ ។

យល់ឃើញថា៖ ការលើកឡើងនៅក្នុងសារណាចុះថ្ងៃទី១៣.៣.៩៨ របស់អ្នកស្រីឡុបណរដែលថា អ្នកស្រីបានផ្ទេរបំណុលនេះអោយទៅអ្នកស្រីចាន់ ស៊ីណាត សងជំនួសដោយពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកស្រី ពយ នោះ តុលាការពុំអាចពិចារណាបានឡើយ ។ ហើយការដែលអ្នកស្រីទាមទារបង់សង១ខែចំនួន ២០ដុល្លាអាមេរិក នោះក៏តុលាការកំពូលពុំមាន-សមត្ថកិច្ចពិចារណាបានដែរពីព្រោះថា ៖ អ្នកស្រីជំពាក់ប្រាក់គេតាំងពីឆ្នាំ ១៩៩៤ រហូតដល់ឆ្នាំ ១៩៩៧ ម្ចាស់បំណុលសុខចិត្តធ្វើកិច្ចសន្យាអោយសង ១ខែ ២០ដុល្លាអាមេរិក ប៉ុន្តែអ្នកស្រីនៅតែ-ពុំព្រមសងទៀត ទើបម្ចាស់បំណុលប្តឹងមកតុលាការសុំអោយអ្នកស្រីសងគ្រប់ចំនួនទាំងអស់តែម្តង។

យល់ឃើញថា ៖ សាលដីការដ្ឋប្បវេណីលេខ ៧៥៤ ចុះថ្ងៃទី ១៥.១២.៩៧ របស់សាលាឧទ្ធរណ៍-ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គិតច្បាប់ហើយលើកលែង-ប្រាក់ពន្ធសមាមាត្រដែលត្រូវកែតម្រូវ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ១៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ ១៩៩៨ របស់អ្នកស្រីឡុបណរទុក្ខជា-ត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៧៥៤ ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ទុកជា-បានការដោយកែតម្រូវអំពីពន្ធសមាមាត្រ ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៨.០០០រៀល ដែលអ្នកស្រី ពយ បានបង់ជួស រួចហើយគឺ៖

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់-ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់
- ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវអោយ-អ្នកស្រី ឡុបណរសងប្រាក់ចំនួន ១៩.០០០រៀល នេះទៅអ្នកស្រីពយ វិញ ។

  បង្គាប់អោយអ្នកស្រី ឡេង ប៊ុនណ្ណារី បង់ពន្ធសមាមាត្រ ១ភាគរយលើចំនួនប្រាក់ដើម ការប្រាក់ និងជម្ងឺចិត្ត ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ។